# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

### កំណត់ហេតុ

**ស្តីពីការព្យួរកិច្ចសន្យាការងារនៅក្រុមហ៊ុន យូ ឈី ស៊ីលស្គ្រីន ឯ.ក**
**ចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ ដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣**

ឆ្នាំពីរពាន់ម្ភៃបី ខែមិថុនា ថ្ងៃទីដប់បួន វេលាម៉ោងប្រាំបួនព្រឹក នៅក្រុមហ៊ុន **យូ ឈី ស៊ីលស្គ្រីន ឯ.ក** អាសយដ្ឋានភូមិ ព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ ខេត្តកណ្ដាល មានកម្មករនិយោជិតសរុប ១២៦នាក់ ស្រី ៨៨នាក់ និងត្រូវបានព្យួរកិច្ចសន្យាការងារទាំងអស់ ចំនួន ២០នាក់ រយៈពេល០២ខែ។ ក្រោមអធិបតីភាពលោក ONG KWEETONG ជានាយកក្រុមហ៊ុន។

**សមាសភាពចូលរួមមាន៖**

**ភាគីក្រុមហ៊ុន**

| | |
|---|---|
| លោក ONG KWEETONG | ជានាយកក្រុមហ៊ុន |
| កញ្ញា ថុល ចាន់ថូរ | ជារដ្ឋបាលក្រុមហ៊ុន |
| អ្នកស្រី សឿង ស៊ីណា | ជាគណនេយ្យ |

**ភាគីតំណាងកម្មករ/ សហជីព**

| | | |
|---|---|---|
| ១-លោកស្រី | នី ស្រីទី | ជាប្រតិភូបុគ្គលិកជំនួយ |
| ២-លោក | លី សុភក័ | ជាប្រតិភូបុគ្គលិកពេញសិទ្ធ |
| ៣-លោក | ស៊ឹម រស់ | ជាប្រតិភូបុគ្គលិកពេញសិទ្ធ |
| ៤-លោកស្រី | សន ឡៅ | ជាប្រតិភូបុគ្គលិកជំនួយ |

**ភាគីក្រុមហ៊ុន**

លោកនាយកក្រុមហ៊ុនបានថ្លែងអំណរគុណដល់ភាគីតំណាងកម្មករ ដែលបានអញ្ជើញចូលរួមប្រជុំក្នុងពេលនេះ និងសូមឲ្យបងប្អូនកម្មករនិយោជិតយោគយល់ពីស្ថានភាពក្រុមហ៊ុនដែលកំពុងជួបការលំបាកផ្នែកសេដ្ឋកិច្ច ដែលបណ្តាលមកពីកង្វះវត្ថុធាតុដើម និងមិនមានការបញ្ជាទិញគ្រប់គ្រាន់ ដែលជាមូលហេតុធ្វើអោយសង្វាក់ផលិតកម្មមិនអាចដំណើរការឲ្យបងប្អូនកម្មករនិយោជិតបានធ្វើការពេញលេញដូចមុនឡើយ។ ដូចនេះថ្នាក់ដឹកនាំរបស់ក្រុមហ៊ុន សម្រេចព្យួរកិច្ចសន្យាការងាររបស់បងប្អូនកម្មករនិយោជិតទាំងអស់ ២០នាក់ ក្នុងនោះមានស្រីចំនួន ១៣នាក់ ក្នុងរយៈពេល ០២ខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន យូ ឈី ស៊ីលស្គ្រីន ឯ.ក YOU QI SILKSCREEN CO., LTD. KINGDOM OF CAMBODIA

**<u>ភាគីតំណាងកម្មករ/សហជីព</u>**

បងប្អូនកម្មករនិយោជិតឯកភាពនិងទទួលស្គាល់ពីផលលំបាករបស់ក្រុមហ៊ុនដែលបណ្ដាលឲ្យមានការស្នើសុំព្យួរកិច្ចសន្យាការងារ ដូច្នេះស្នើសុំឲ្យក្រុមហ៊ុនអនុវត្តការព្យួរកិច្ចការងារនេះឲ្យបានត្រឹមត្រូវទៅតាមច្បាប់។

**<u>លទ្ធផលនៃការពិភាក្សា</u>**

ភាគីទាំងពីរឯកភាពគ្នាដូចខាងក្រោម៖

១.ការព្យួរកិច្ចសន្យាការងារ មានរយៈពេលពីរខែ ដោយគិតចាប់ពីថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២៣។

២.ភាគីកម្មករនិយោជិត បានឯកភាពទទួលយកនូវការផ្ដល់ជូនរបស់ក្រុមហ៊ុន តាមសេចក្ដីណែនាំលេខ ០២០/២៣ ក.ប/ស.ណ.ន.ខ.ល ចុះថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២៣ ស្ដីពីការព្យួរកិច្ចការងាររបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។ភាគីក្រុមហ៊ុន ឯកភាពផ្ដល់ប្រាក់ឧបត្ថម ៣០$ ( សាមសិបដុល្លារអាមេរិច)ក្នុងមួយខែ និងកំណត់បើកជូននៅរៀងរាល់ថ្ងៃទី១០ នៃខែបន្ទាប់។

៣.ប្រសិនបើក្រុមហ៊ុនមានការងារធ្វើឡើងវិញ ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារ ក្រុមហ៊ុននឹងជូនដំណឹងដល់បងប្អូនកម្មករ ហើយបងប្អូនកម្មករត្រូវចូលធ្វើការងារតាមការជូនដំណឹងរបស់ក្រុមហ៊ុន។

៤.ភាគីកម្មករនឹងត្រូវចូលបម្រើការងារតាមការជូនដំណឹងរបស់ក្រុមហ៊ុន ប្រសិនបើក្រុមហ៊ុនមានការងារធ្វើក្នុងអំឡុងពេលនៃការងារស្នើសុំព្យួរកិច្ចសន្យាការងារនេះ ហើយបន្ទាប់ពីការជូនដំណឹងក្នុងរយៈពេល ០៦ ថ្ងៃ កម្មករនិយោជិតមិនបានចូលបំពេញការងារតាមការជូនដំណឹងនោះទេ ក្រុមហ៊ុនចាត់ទុកកម្មករនិយោជិតនោះបានប្រព្រឹត្តកំហុសធ្ងន់ដោយយោងតាមបទបញ្ជាផ្ទៃក្នុងក្រុមហ៊ុននឹងបញ្ឈប់កម្មករនិយោជិតនោះពីការងារ។

៥.ការបើកប្រាក់ឈ្នួលព្យួរកិច្ចសន្យាការងារ ត្រូវធ្វើឡើងពីរដងក្នុងមួយខែ គឺនៅថ្ងៃទី ២៥ និងថ្ងៃទី១០ នៃខែនីមួយៗ។

កិច្ចប្រជុំបានចប់សព្វគ្រប់វេលាម៉ោង១០.៣០នាទី នាថ្ងៃខែឆ្នាំដដែល។

| **តំណាងក្រុមហ៊ុន** | **តំណាងកម្មករ** |
|---|---|
| ថុល ចាន់ថូរ | ស៊ឹម រស់ |
| សឿង ស៊ីណា | លី សុភក័ |
| | សន ឡៅ |
| | នី ស្រីទី |

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន យូ ឈី ស៊ីលស្គ្រីន ឯ.ក YOU QI SILKSCREEN CO.,LTD. KINGDOM OF CAMBODIA